ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា ( DTA ) រវាងព្រះរាជាណាចក្រកម្ពុជានិងសាធារណរដ្ឋសិង្ហបុរី

អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនសាធារណជនឲ្យបានជ្រាបថា កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៦ កន្លងទៅ ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសិង្ហបុរី បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (Double Tax Avoidance - DTA)និងការបង្ការការគេចវេះពន្ធពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល។

ពិធីចុះហត្ថលេខានេះត្រូវបានចុះហត្ថលេខាដោយឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលោកជំទាវ **ឥន្រ្ទានី រ៉ាចា** (Indranee Rajah), Senior Minister of State for Law and Finance នៃសាធារណរដ្ឋសិង្ហបុរី។

កិច្ចព្រមព្រៀងនេះ ត្រូវបានធ្វើឡើងក្នុងបំណងផ្តល់អត្ថប្រយោជន៍ដល់ប្រទេសជាហត្ថលេខី លើកិច្ចការពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី, ធ្វើឲ្យប្រាកដប្រជាក្នុងការកំណត់សិទ្ធិនៃការយកពន្ធ, កំណើនមូលដ្ឋានគិតពន្ធតាមរយៈការទាក់ទាញវិនិយោគដោយផ្ទាល់, លំហូរមូលធន,ការផ្ទេរបច្ចេកវិទ្យា និងជំនាញពីបរទេស, ការការពារនិវាសនជនពីប្រព្រឹត្តកម្មមិនត្រឹមត្រូវពាក់ព័ន្ធនឹងពន្ធ និងការការពារចំណូលពន្ធ ក្នុងស្រុកតាមរយៈកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងនឹងការគេចវេះពន្ធ រវាងប្រទេសទាំងពីរ។ កិច្ចព្រមព្រៀងនេះ នឹងចូលជាធរមាននៅពេលដែលប្រទេសទាំងពីរផ្តល់សច្ចាប័នរួចរាល់។

នេះគឺជាកិច្ចព្រមព្រៀងទីមួយបង្អស់របស់ព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានចុះហត្ថលេខា និងជាសមិទ្ធផលថ្មីមួយទៀតក្នុងចំណោម សមិទ្ធផលសំខាន់ៗជាច្រើន ដែលរាជរដ្ឋាភិបាលនីតិកាលទីប្រាំនៃរដ្ឋសភា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សម្រេចបាន ជាពិសេសក្នុងបរិបទនៃសមាហរណកម្មសេដ្ឋកិច្ចអាស៊ានដែលទើបតែចាប់ផ្តើម នាពេលថ្មីៗនេះ។

ព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងធ្វើការចរចាលើកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា ជាមួយបណ្តាប្រទេសអាស៊ាន និងអាស៊ីជាដៃគូមួយចំនួនទៀត ដូចជា ថៃឡង់ដ៏, ម៉ាឡេស៊ី, ប្រ៊ុយណេ, ចិន, ជប៉ុន និងកូរ៉េ ជាដើម៕

អគ្គនាយកដ្ឋានពន្ធដារ